**UNITED NATIONS**
CAMBODIA OFFICE OF THE
HIGH COMMISSIONER FOR HUMAN RIGHTS

**NATIONS UNIES**
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

Special Representative of the Secretary-General
for Human Rights in Cambodia
តំណាងពិសេសរបស់លោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

COHCHR

## លោកតំណាងពិសេសសំដែងការព្រួយបារម្ភជាខ្លាំងចំពោះសាលក្រមរបស់តុលាការពីបទបរិហារកេរ្តិ៍ចំពោះ មេដឹកនាំគណៈបក្សប្រឆាំង លោក សម រង្ស៊ី ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៥

លោកតំណាងពិសេសអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា លោកយ៉ាសហ៊ី ហ្គាយ មានការព្រួយបារម្ភចំពោះការកាត់ទោសកំបាំងមុខមេដឹកនាំគណៈបក្សប្រឆាំងគឺ លោក សម រង្ស៊ី ដែលតុលាការក្រុងភ្នំពេញបានប្រកាសសាលក្រម កាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៥ នេះ។

តុលាការក្រុងភ្នំពេញបានកាត់ទោសលោកសម រង្ស៊ី ឱ្យជាប់ពន្ធនាគារ ១៨ខែ និងបង្គាប់ឱ្យបង់ប្រាក់សំណងចំនួន ៥៦លានរៀល ពីបទចោទប្រកាន់ថាបានបរិហារកេរ្តិ៍ព្រះអង្គម្ចាស់នរោត្តម រណឬទ្ធិ ប្រធានគណៈបក្សហ្វុនស៊ីនប៉ិច និងនាយករដ្ឋមន្ត្រីហ៊ុន សែន។ ការចោទប្រកាន់ពីបទបរិហាកេរ្តិ៍នេះធ្វើតាមមាត្រា៦៣ នៃច្បាប់ស្ដីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ឆ្នាំ១៩៩២ (ដែលជាទូទៅគេហៅថាច្បាប់អ៊ុនតាក់) ដែលពាក់ព័ន្ធទៅនឹងបទសម្ភាសន៍មួយរវាងលោកសម រង្ស៊ី ជាមួយវិទ្យុសំបុកឃ្មុំ ដោយធ្វើការចោទថា ព្រះអង្គម្ចាស់នរោត្តម រណឬទ្ធិបានទទួលលុយ ៥០លានដុល្លាអាមេរិក និងយន្តហោះមួយគ្រឿង ពីនាយករដ្ឋមន្ត្រីហ៊ុន សែន ដើម្បីចូលរួមក្នុងការបង្កើតរដ្ឋាភិបាលចំរុះជាមួយគណៈបក្សប្រជាជនកម្ពុជា នាឆ្នាំ២០០៤។ ជាមួយគ្នានេះផងដែរ តុលាការបានរកឃើញថា លោកសម រង្ស៊ី មានពិរុទ្ធភាពពីបទបរិហារកេរ្តិ៍លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ចំពោះបណ្ដឹងដែលលោកសម រង្ស៊ី បានចោទប្រកាន់នាយករដ្ឋមន្ត្រីថាជាអ្នកនៅពីក្រោយការគប់គ្រាប់បែកទៅលើហ្វូងបាតុករកាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៩៧ ដែលបណ្ដាលឱ្យមនុស្សប្រហែល១៤នាក់ស្លាប់ និងរងរបួស១៤២នាក់។ លោកសម រង្ស៊ីបាននិរទេសខ្លួនតាំងពីខែកុម្ភៈ ឆ្នាំ២០០៥មកម្ល៉េះគឺបន្ទាប់ពីរដ្ឋសភាបានដកអភ័យឯកសិទ្ធិរបស់លោកក្នុងសម័យប្រជុំជាសំងាត់មួយ។

សាលក្រមដាក់ទោសលោកសម រង្ស៊ី គឺជាកំរងនៃបទបរិហារកេរ្តិ៍មួយ ដែលធ្វើការចោទប្រកាន់ចំពោះបុគ្គលសាធារណៈនាអំឡុងពេល២ឆ្នាំចុងក្រោយនេះ។ បទចោទប្រកាន់នេះបណ្ដាលឱ្យមានការព្រួយបារម្ភយ៉ាងធ្ងន់ធ្ងរថា នៅកម្ពុជា បទបរិហាកេរ្តិ៍ និងការផ្សព្វផ្សាយព័ត៌មានមិនពិត ត្រូវបានធ្វើការចោទប្រកាន់ ថាជារឿងព្រហ្មទណ្ឌតាមច្បាប់អ៊ុនតាក់ឆ្នាំ១៩៩២ ដោយពុំត្រូវបានធ្វើការចោទប្រកាន់តាមនីតិរដ្ឋប្បវេណីទៅវិញ។ ចំពោះប្រការនេះ លោកតំណាងពិសេសមានជំនឿយ៉ាងមុតមាំថា ទស្សនៈនិងគំនិតផ្ទុយគ្នានេះ គួរត្រូវយកមកពិភាក្សាតទល់គ្នាជាសាធារណៈ ជាជាងធ្វើតាមបណ្ដឹងព្រហ្មទណ្ឌ។ លោកតំណាងពិសេសធ្វើការកត់សំគាល់ថា ច្បាប់អ៊ុនតាក់ដែលបានអនុម័តឱ្យប្រើនោះ គឺសំរាប់ប្រើតែរយៈកាលបណ្ដោះអាសន្ន និងក្នុងកាលៈទេសៈជាក់លាក់មួយតែប៉ុណ្ណោះ ហើយច្បាប់នេះមិនឆ្លុះបញ្ចាំងពីស្ថានភាពបច្ចុប្បន្ននៅកម្ពុជាឡើយ។ មិនត្រឹមតែប៉ុណ្ណោះ ច្បាប់នេះត្រូវបានអនុម័តមុនពេលប្រទេសកម្ពុជាបានអនុម័តរដ្ឋធម្មនុញ្ញរបស់ខ្លួនដែលបានទទួលស្គាល់សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិសំខាន់ៗមួយចំនួន ជាពិសេសកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

លោកតំណាងពិសេសយល់ឃើញថា បញ្ញត្តិដែលទាក់ទងទៅនឹងបទល្មើសព្រហ្មទណ្ឌចំពោះការផ្សព្វផ្សាយព័ត៌មានមិនពិត និងការបរិហារកេរ្តិ៍តាមមាត្រា៦២ និង៦៣នៃច្បាប់អ៊ុនតាក់នោះ មិនអនុលោមទៅតាមទាំងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងទាំងការប្ដេជ្ញាចិត្តរបស់ខ្លួនចំពោះសិទ្ធិមនុស្សអន្តរជាតិឡើយ។ ហេតុនេះហើយ បទបញ្ញត្តិដែលសេសសល់ពីអតិតកាលដ៏ចំរូងចំរាស់របស់កម្ពុជា ត្រូវតែយកមកពិចារណាអោយបានហ្មត់ចត់ ដើម្បីលុបចោល។ ក្រមព្រហ្មទណ្ឌថ្មី ដែលកំពុងតែរៀបចំតាក់តែងសព្វថ្ងៃនេះ ក៏បានផ្ដល់ឱកាសមួយស្វាគមន៍ចំពោះការធ្វើវិសោធនកម្មច្បាប់ ដើម្បីធ្វើអោយច្បាប់ទាំងនោះ ស្របទៅនឹងរដ្ឋធម្មនុញ្ញ និងកាតព្វកិច្ចរបស់ប្រទេសកម្ពុជាចំពោះសន្ធិសញ្ញានានា។ ក្នុងបរិបទនេះ លោកតំណាងពិសេសមានបំណងប្រាថ្នាគូសបញ្ជាក់ផងដែរថា កម្ពុជាពិតជាត្រូវការនូវប្រព័ន្ធយុត្តិធម៌មួយដែលឯករាជ្យ មិនលំអៀងនិងអាចទុកចិត្តបាន។ នេះរឹតតែមានសារៈសំខាន់ណាស់ទៅទៀត នៅពេលដែលឱកាសសំរាប់ការបញ្ចេញមតិនយោបាយ និងការជជែកវែកញែកជាសាធារណៈកាន់តែប្រឈមមុខទៅរួមទាំងតាមរយៈតុលាការផងដែរ។

ក្នុងពេលទស្សនៈកិច្ចរបស់លោកនាពេលថ្មីៗនេះ លោកតំណាងពិសេសបានជ្រាបពីការចាប់ខ្លួន និងការឃុំខ្លួនឥស្សរជននយោបាយមួយចំនួន អ្នកសារព័ត៌មាន និងសហជីពកម្មករ ហើយលោកក៏បានជ្រាបផងដែរពីការដកអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រគណៈបក្សប្រឆាំង។ លោកមានការព្រួយបារម្ភផងដែរពីភាពមិនប្រក្រតីជាច្រើន ដែលលោកបានទទួលពាក់ព័ន្ធលើករណីទាំងនេះ។ និន្នាការគួរឱ្យព្រួយបារម្ភយ៉ាងខ្លាំងនេះ គឺជាការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់សេរីភាពនៃការបញ្ចេញមតិ និងនយោបាយពហុបក្ស នៅប្រទេសកម្ពុជា។ សាលក្រមដាក់ទោសលោកសម រង្ស៊ី ត្រូវបានគេមើលឃើញដូចអ្វីដែលបានរៀបរាប់នេះ។ លោកតំណាងពិសេសសូមអំពាវនាវឱ្យមានការដោះលែងជាបន្ទាន់ដល់លោកម៉ម សូណង់ដូ អ្នកផ្សាយព័ត៌មានវិទ្យុសំបុកឃ្មុំ លោករ៉ុង ឈុន សកម្មជនសហជីព និងតំណាងរាស្ត្រ ជាម ច័ន្ទនី ជាទង្វើមួយដែលនឹងត្រូវបានទទួលស្វាគមន៍ដោយសហគមន៍អន្តរជាតិ ក៏ដូចជាសញ្ញាមួយនៃការប្ដេជ្ញាចិត្តរបស់ប្រទេសកម្ពុជា ក្នុងការបន្តធានា លើកកំពស់ និងការការពារដល់សិទ្ធិ និងសេរីភាព។

#10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh, Cambodia.
Tel: (855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: (855) 23 212 579 or 213 587 E-mail: cohchr@online.com.kh
ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា លេខ ១០ ផ្លូវលេខ ៣០២ សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន ភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: ៨៥៥-២៣ ៩៨៧ ៦៧១ / ៩៨៧ ៦៧២ / ៩៩៣ ៥៩០ / ៩៩៣ ៥៩១ / ឬ ២១៦ ៣៤២ ទូរសារ: ៨៥៥-២៣ ២១២ ៥៧៩ ឬ ២១៣ ៥៨៧